# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាសម្រាប់បូជាចារ្យទាំងអស់នៅក្នុងព្រះសហគមន៍
# ចំការទៀង ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០
# រស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់

**អត្ថបទទី១៖ ពង្សាវតារក្សត្រទី២ ៤,៨-១១,១៤-១៦ក**

លោកមានប្រសាសន៍ថា៖ «ចូរហៅនាងមក»។ ២ពង្ស ៤,១៥

**អត្ថបទទី២៖ រ៉ូម ៦,៣-៤,៨-១១**

ខ្ញុំប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រិស្ត យើងក៏ជឿថា យើងនឹងមានជីវិតរួមជាមួយព្រះអង្គដែរ។ រម ៦,៨

**ដំណឹងល្អ៖ ម៉ាថាយ ១០,៣៧-៤២**

អ្នកណាទទួលមនុស្សសុចរិតម្នាក់ក្នុងនាមជាមនុស្សសុចរិត អ្នកនោះនឹងទទួលរង្វាន់ដូចមនុស្សសុចរិត។ មថ ១០,៤១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងនឹករលឹកដល់ជីវិតរបស់បូជាចារ្យនៅក្នុងភូមិភាគភ្នំពេញ ជាឱកាសមួយនឹកឃើញដល់របៀបដែលព្រះជាម្ចាស់បានត្រាស់ហៅយើង ដើម្បីប្រកាសដំណឹងល្អ។ "**សូមឲ្យយើងធ្វើជាព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់នៅលើផែនដីនេះ**" ជាចំណងជើងរូបដែលគូរដោយបងស្រីម្នាក់នៅទីក្រុងយេរ៉ូសាឡឹម មានព្រះនាងម៉ារីកំពុងដើរទៅជួបព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ នៅខាងក្រោយព្រះនាងម៉ារី មានគ្រីស្តទូតតែ១១នាក់ មិនមែនបាត់ម្នាក់ដោយសារយូដាស់ក្បត់ ប៉ុន្តែគ្រីស្តទូតទី១២គឺអ្នកដែលបានមើលរូបនេះ។ ដូច្នេះ ពេលយើងមើលរូបនេះ យើងយល់ថា ខ្ញុំបានចូលនៅក្នុងក្រុមគ្រីស្តទូតនេះ។ សម្រាប់ខ្ញុំ ខ្ញុំបានចាប់អារម្មណ៍ណាស់ដោយសារព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ឲ្យខ្ញុំចូលនៅក្នុងក្រុមគ្រីស្តទូតដើម្បីធ្វើដំណើរជាមួយព្រះនាងម៉ារី។ រូបនេះគេកំពុងដើរលើទឹក ដែលណែនាំឲ្យយើងនឹកឃើញលោកសិលា ពេលគាត់នៅលើទឹកសមុទ្រដែលមានខ្យល់ នៅពេលនោះលោកសិលាភ័យខ្លាចមែនទែន តែព្រះយេស៊ូកំពុងដេកលក់។ ប៉ុន្តែ ព្រះយេស៊ូមិនមែនកំពុងដេកលក់ គឺព្រះយេស៊ូគង់នៅដើម្បីថែរក្សាគេដោយមានព្រះបន្ទូលថា "**កុំខ្លាចអី! កុំខ្លាចអីខ្ញុំទេតើ! កុំខ្លាចអីខ្ញុំធ្វើដំណើរជាមួយអ្នក!**"។

នៅក្រោមព្រះយេស៊ូ (លើរូបនេះ) មានពាងទឹក៦ ដែលណែនាំឲ្យយើងនឹកឃើញដល់មង្គលការនៅភូមិកាណា ពេលព្រះយេស៊ូបានបង្ហាញព្រះហឫទ័យស្រឡាញ់មុនគេបង្អស់ ព្រះអង្គបានប្រែទឹកទៅជាស្រា ដើម្បីណែនាំឲ្យប្រជាជនមានអំណរសប្បាយ។ យើងឃើញព្រះហស្តរបស់ព្រះនាងម៉ារី បានចូលនៅក្នុងព្រះបេះដូងរបស់ព្រះយេស៊ូ ដោយសារព្រះនាងម៉ារីនៅជាមួយ

យើងផង ព្រះនាងនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះយេស៊ូផង។ ព្រះនាងម៉ារី បានទាក់ទាញយើងដើម្បីឲ្យយើងធ្វើដំណើរដល់ព្រះយេស៊ូដែលកំពុងស្វាគមន៍យើង។ ព្រះហស្តរបស់ព្រះយេស៊ូ កំពុងបើកស្វាគមន៍យើង ព្រះយេស៊ូមានអាវពណ៌ស និងមានស្នាមរបួសនៅឆ្អឹងជំនីណែនាំឲ្យយើងនឹកឃើញពេលគេយកលំពែងចាក់ទម្លុះបេះដូងព្រះយេស៊ូ នៅពេលនោះមានទឹកនិងឈាមហូរចេញមក។ ទឹកនិងឈាម ជាសញ្ញាសម្គាល់នៃជីវិតដែលយើងបានទទួលពីព្រះយេស៊ូ ជាសញ្ញាសម្គាល់ដែលព្រះយេស៊ូកំពុងបង្កើតព្រះសហគមន៍ ដើម្បីឲ្យព្រះសហគមន៍រួមរស់នៅក្នុងសេចក្ដីស្រឡាញ់ដែលយើងទទួលពីព្រះយេស៊ូ ដើម្បីឲ្យព្រះសហគមន៍ជម្រះចិត្តគំនិតរបស់មនុស្សលោក ដើម្បីឲ្យយើងមានជីវិត។

ពេលយើងមើលរូបនេះ ធ្វើឲ្យយើងអរព្រះគុណព្រះជាម្ចាស់ ដែលបានណែនាំឲ្យយើងជាបូជាចារ្យ រស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ដើម្បីណែនាំឲ្យព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ កើតឡើងជារូបរាងលើផែនដីនេះ។ នៅក្នុងអត្ថបទគម្ពីរយើងឃើញហើយ ដើរតាមព្រះយេស៊ូមិនស្រួលទេ ព្រះអង្គមានព្រះបន្ទូលយ៉ាងច្បាស់ថ្ងៃនេះ។ ឲ្យយើងស្រឡាញ់ព្រះយេស៊ូជាអាទិភាព យើងយកព្រះយេស៊ូជាទីពឹងរបស់យើង យើងយកព្រះយេស៊ូជាអាទិភាពនៅក្នុងជីវិតរបស់យើងដើម្បីធ្វើដំណើរ។ ដោយដឹងថា ប្រសិនបើយើងមិនលីឈើឆ្កាង ប្រសិនបើយើងមិនយកធ្នឹមដែលមាននៅក្នុងជីវិតដើម្បីដើរតាមព្រះយេស៊ូ យើងមិនអាចទៅមុខបានទេ។ ប៉ុន្តែ ឈើឆ្កាងនេះព្រះយេស៊ូជួយយើងដើម្បីឲ្យយើងលីបាន ដើម្បីឲ្យយើងមានកម្លាំងមិនឲ្យឈើឆ្កាងយើងធ្ងន់ពេក។ ព្រះយេស៊ូធ្វើដំណើរជាមួយយើងដោយមានព្រះបន្ទូលថា "**កុំខ្លាចអី! ខ្ញុំទេតើ ខ្ញុំកំពុងធ្វើដំណើរជាមួយអ្នក**"។

ខ្ញុំមានបីចំណុច សម្រាប់យើងដែលជាបូជាចារ្យ គឺៈ

**ទីមួយ ព្យាការី** ជាអ្នកដែលថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្យាការីជាអ្នកដែលបង្ហាញផ្លូវឲ្យយើងស្គាល់ដំណើរជីវិត។ យើងថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយបង្ហាញតាមជីវិតផ្ទាល់ខ្លួនថា **តើព្រះជាម្ចាស់ជានរណា ដើម្បីស្រឡាញ់យើងដូចនេះ? តើព្រះជាម្ចាស់ជានរណា ដើម្បីធ្វើដំណើរជាមួយមនុស្សដូចនេះ?** ព្រះជាម្ចាស់មានឫទ្ធានុភាពសព្វប្រកាស ព្រះជាម្ចាស់មានអ្វីៗទាំងអស់នៅក្នុងព្រះហស្តរបស់ព្រះអង្គ ប៉ុន្តែព្រះអង្គបានបង្កើតយើងដោយសារព្រះអង្គចង់ឲ្យមនុស្សយើង ទៅជាឧបករណ៍ណែនាំសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ទៅដល់គ្រប់ទីកន្លែងលើផែនដីនេះ។ ដូច្នេះ ព្យាការីមិនចេះតែនិយាយច្រើនលើបបូរមាត់ គឺព្យាការីដែលប្រកាសដំណឹងល្អតាមរយៈជីវិតផ្ទាល់ខ្លួន។ ដូចយើងបានឃើញនៅក្នុងអត្ថបទទីមួយ លោកអេលីមិនបានតែសម្រាកនៅក្នុងបន្ទប់ដែលយាយបានរៀបចំសម្រាប់គាត់ លោកអេលីបានណែនាំឲ្យការសង្គ្រោះ ឲ្យជីវិតទៅ

ដល់យាយម្នាក់ហ្នឹងនឹងមានកូនប្រុសមួយ ដោយសារនេះជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់តាមរយៈព្យាការី។

**ទីពីរ មនុស្សសុចរិត** ព្រះជាម្ចាស់បានជ្រើសរើសយើងដើម្បីឲ្យយើងរស់នៅក្នុងភាពសុចរិត ដើម្បីឲ្យយើងរស់នៅក្នុងពន្លឺរបស់ព្រះអង្គ។ ជីវិតរបស់យើង ជាជីវិតដែលធ្វើដំណើរជាមួយព្រះអង្គដោយដឹងថា ព្រះជាម្ចាស់មានព្រះហឫទ័យភក្ដីជាមួយយើង **តើយើងធ្វើដូចម្ដេចដើម្បីស្ម័គ្រស្លាប់ ស្ម័គ្ររស់ជាមួយព្រះយេស៊ូដែលជាជីវិតរបស់យើងនៅក្នុងភាពសុចរិត?**

**ទីបី សាវ័ក** ឲ្យយើងធ្វើជាសាវ័កដែលដើរតាមព្រះយេស៊ូ សាវ័កដែលណែនាំឲ្យបងប្អូនឯទៀតៗអាចរកឃើញការសង្គ្រោះពីព្រះអង្គ។ យើងត្រូវការនឹកឃើញ យើងធ្វើដូចម្ដេចដើម្បីឲ្យជីវិតរបស់ព្រះជាម្ចាស់ទៅដល់គ្រប់ទីកន្លែង។ ថ្ងៃនេះ យើងមានចម្លើយពីព្រះយេស៊ូផ្ទាល់គឺ "**សូម្បីតែអ្នកណាឲ្យទឹកត្រជាក់មួយកែវដល់អ្នកតូចតាចម្នាក់នៅក្នុងនាមជាសាវ័ករបស់ខ្ញុំ ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកនោះនឹងទទួលរង្វាន់ជាមិនខាន**"។ ទឹកត្រជាក់មួយកែវ ជាសញ្ញាសម្គាល់នៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ឲ្យយើងរស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់លើផែនដីនេះ។ ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ គឺជាសញ្ញាតូចតាចដែលយើងធ្វើនៅក្នុងជីវិតរបស់យើងផ្ទាល់ ដើម្បីណែនាំឲ្យបងប្អូនរបស់យើងមានសេចក្ដីសង្ឃឹម។ មិនមែនជាស្នាដៃអស្ចារ្យ ពេលយើងចេះបើកភ្នែកយើងឃើញសេចក្ដីត្រូវការ យើងមើលរបៀបព្រះយេស៊ូពេលព្រះអង្គបានចាប់ផ្ដើមប្រកាសដំណឹងល្អ ព្រះអង្គឃើញសេចក្ដីត្រូវការរបស់បងប្អូនឯទៀតៗ។ យើងមិនចាប់គេឲ្យគេចូលព្រះវិហារ មិនចាប់គេឲ្យគេស្គាល់ព្រះជាម្ចាស់តាមរបៀបថ្វាយបង្គំ ផ្ទុយទៅវិញឲ្យយើងធ្វើដំណើរជាមួយគេបន្តិចម្ដងៗ។ បើយើងចាប់អារម្មណ៍អំពីដំណើរជីវិតរបស់ព្រះយេស៊ូ ព្រះអង្គបានបូជាជីវិត ព្រះយេស៊ូបានប្រទានព្រះកាយព្រះគ្រីស្ត នៅថ្ងៃចុងក្រោយព្រះយេស៊ូត្រូវការបីឆ្នាំ ដើម្បីណែនាំទាំងក្រុមគ្រីស្តទូត ទាំងមហាជនឲ្យគេស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ព្រះយេស៊ូបានដើររហូត ព្រះអង្គបានធ្វើដំណើរលើផ្លូវនៃជីវិតរបស់បងប្អូននៅកន្លែងដែលគេនៅ ដើម្បីយល់អំពីសេចក្ដីត្រូវការ ដើម្បីយល់អំពីសេចក្ដីសង្ឃឹម ដើម្បីយល់អំពីរបៀបដែលមនុស្សយើងមានកម្លាំងកាយកម្លាំងចិត្តឬបាក់ទឹកចិត្ត ដើម្បីធ្វើដំណើរចូលយ៉ាងជ្រៅនៅក្នុងចិត្តរបស់មនុស្ស។ ពេលព្រះយេស៊ូជួបជាមួយស្ត្រីសាសន៍សាម៉ារីនៅពេលនោះព្រះយេស៊ូបានចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់ស្ត្រីនោះ ដើម្បីឲ្យគាត់ចេញពីភាពងងឹតនៃជីវិតរបស់គាត់ហើយរកឃើញពន្លឺ។ ពេលព្រះយេស៊ូជួបជាមួយលោកសាខេក៏ដូចគ្នាដែរ ព្រះយេស៊ូបានចូលនៅក្នុងភាពងងឹតនៃជីវិតរបស់លោកសាខេ ដោយទៅបរិភោគនៅផ្ទះគាត់។ លោកសាខេមិនបានអញ្ជើញព្រះយេស៊ូទេ គឺព្រះយេស៊ូផ្ទាល់ដែលបានអញ្ជើញខ្លួនឯងទៅ

ផ្ទះលោកសាខេ។ នៅពេលនោះ ព្រះយេស៊ូមិនបានទៅតែដើម្បីបរិភោគ ប៉ុន្តែព្រះអង្គចូលនៅក្នុងដួងចិត្តរបស់លោកសាខេ ដើម្បីមើលឃើញភាពងងឹតនៅក្នុងជីវិតរបស់គាត់ ដើម្បីបង្ហាញភាពងងឹតនោះឲ្យគាត់ឃើញ។ នៅពេលនោះលោកសាខេគាត់ភ្លឺនៅក្នុងរបៀបថ្មី និងមានជីវិតថ្មីដោយចែករំលែកទ្រព្យសម្បត្តិរបស់គាត់ដល់អ្នកក្រីក្រ។ នេះជារបៀបរបស់ព្រះយេស៊ូ ជារបៀបដែលយើងត្រូវការធ្វើដំណើរជាមួយបងប្អូន ដើម្បីណែនាំឲ្យព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់កើតឡើងលើផែនដីនេះ។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គបន្តបំភ្លឺយើងឲ្យយើងធ្វើជាព្យាការី ឲ្យយើងធ្វើជាមនុស្សសុចរិត ឲ្យយើងធ្វើជាសាវ័ក ដើម្បីរួមរស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គដោយដឹងថាព្រះជាម្ចាស់មិនទន្ទឹងរង់ចាំការអស្ចារ្យពីយើង ព្រះអង្គទន្ទឹងរង់ចាំតែសេចក្តីស្រឡាញ់ដែលជាសញ្ញាសម្គាល់ នៃវត្តមានរបស់ព្រះយេស៊ូលើផែនដីនេះដ៏ពិតប្រាកដមែន។ អាម៉ែន៕